# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខៈ ១០៣៦ គ.ជ.ប

## សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គ.ជ.ប ត្រូវការជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ចំនួន **១.៦៤៦ ក្រុម** ស្មើនឹង ចំនួន **៣.៤៩២ នាក់** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមឃុំ សង្កាត់ នៃរាជធានី ខេត្ត សម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ដែលមានមុខតំណែងដូចខាងក្រោម ៖

១- ប្រធានក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)
២- សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន (សម្រាប់ឃុំ សង្កាត់ ជាក់ស្តែងមួយចំនួន)
៣- សមាជិក ក.ច.ប ជាការីកុំព្យូទ័រ

បេក្ខជនដែលមានបំណងដាក់ពាក្យសុំបម្រើការងារតាមមុខតំណែងខាងលើ សូមអញ្ជើញទៅមើលសេចក្តីជូនដំណឹងស្តីពីការជ្រើសរើស លក្ខខណ្ឌជ្រើសរើស និងការដាក់ពាក្យ ការទទួលពាក្យ ដែលនឹងបិទផ្សាយចាប់ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ នៅតាមសាលាឃុំ សង្កាត់ និងទីកន្លែងសាធារណៈក្នុងឃុំ សង្កាត់ ដែល គ.ជ.ប បានកំណត់ ។

ពាក្យសុំចូលបម្រើការងារនឹងមានចែកជូននៅតាមសាលាឃុំ សង្កាត់ ដោយឥតគិតថ្លៃ ។

- ចាប់ផ្តើមចែកពាក្យ និងទទួលពាក្យសុំប្រឡង ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ (វេលាម៉ោង ៧:០០ព្រឹក)
- ឈប់ទទួលពាក្យសុំប្រឡង ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ (វេលាម៉ោង ១៧:៣០នាទីល្ងាច) ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៧
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ស៊ិក ប៊ុនហុក